# បញ្ញត្តិ

ឧទ្ទេសនាមដោយ
លោកមេធាវី អ៊ីវ ប៉ូលី
លោកស្រីមេធាវី ទេព បូផល

22/10/2017

# មតកសាសន៍ គឺជាអ្វី ?




ដីនិង ផ្ទះរបស់ខ្ញុំប្រគល់អោយកូន...



# តើអ្វីទៅជាមតកសាសន៍?




មតកសាសន៍ ជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីបង្ហាញឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។

# អ្វីទៅជាមតកសាសន៍?




ក្រ.រដ្ឋប្បវេណី

- បទបញ្ញត្តិទូទៅ (គន្ថី១)
- បុគ្គល (គន្ថី២)
- សិទ្ធិប្រត្យក្ស (គន្ថី៣)
- កាតព្វកិច្ច (គន្ថី៤)
- កិច្ចសន្យាសំខាន់ៗ (គន្ថី៥)
- ការធានាកាតព្វកិច្ច (គន្ថី៦)
- ញាតិ (គន្ថី៧)
- សន្តតិកម្ម (គន្ថី៨)
- អវសានប្បញ្ញត្តិ (គន្ថី៩)

# មាតិកា

I ដំណាក់កាលរៀបចំមតកសាសន៍

១. សមត្ថភាពក្នុងការធ្វើមតកសាសន៍

២. ទម្រង់នៃមតកសាសន៍

៣. ចំណុចដែលត្រូវសរសេរនៅក្នុងមតកសាសន៍

៤. ការលុបចោលមតកសាសន៍

II ដំណាក់កាលបង្កើតអានុភាពនៃមតកសាសន៍

III ដំណាក់កាលអនុវត្តមតកសាសន៍

# I. ដំណាក់កាលបង្កើតមតកសាសន៍

- នៅក្នុងដំណាក់កាលនេះ ជាដំណាក់កាលដំបូងដែលយើងត្រូវពិចារណាអំពី សមត្ថភាពរបស់បុគ្គលដែល មានបំណងធ្វើមតកសាសន៍ តើគាត់ជាបុគ្គលដែលច្បាប់ទទួលស្គាល់នូវការបង្ហាញឆន្ទៈរបស់គាត់ឬទេ?
- នាពេលដែលគាត់តាក់តែងមតកសាសន៍ តើគាត់ជាមនុស្សដែលមានស្មារតីល្អ យល់ដឹងអំពីទង្វើរបស់ខ្លួនឯងឬទេ?
- តើគាត់ត្រូវតាក់តែងមតកសាសន៍តាមទម្រង់បែបណា?
- តើចំណុចអ្វីខ្លះដែលត្រូវសរសេរចូលក្នុងមតកសាសន៍ ?

# ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍

- នៅក្នុងចំណុចនេះ យើងពិចារណាអំពី ២ចំណុចដូចខាងក្រោម
- សមត្ថភាពអាចធ្វើមតកសាសន៍ និង សមត្ថភាពនាពេលធ្វើមតកសាសន៍ ។ បុគ្គលខ្លះ ជាបុគ្គលដែលត្រូវបានច្បាប់កំណត់ថា ជាបុគ្គលដែលមានសមត្ថភាព ឬ លក្ខណៈសម្បត្តិអាចធ្វើមតកសាសន៍បាន ប៉ុន្តែ នាពេលដែលគាត់ធ្វើមតកសាសន៍ គាត់អាចជាបុគ្គលដែលស្ថិតក្នុងស្ថានភាពដែលខ្វះសមត្ថភាពខាងឆន្ទៈ ហេតុនេះ ទើបច្បាប់ធ្វើការបែងចែកដូចខាងលើ ដើម្បីងាយស្រួល ក្នុងការវាយតម្លៃ ។

# ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍





បានអាត្តាធីនភាព

**សមត្ថភាពអាចធ្វើមតកសាសន៍៖** នីតិជនគឺជាបុគ្គលដែលច្បាប់កំណត់ថា អាចធ្វើមតកសាសន៍បាន ហេតុនេះ អនីតិជន មិនអាចធ្វើមតកសាសន៍បានទេ លើកលែងតែអនីតិជនដែលបានទទួលអត្តាធីនភាព (មាត្រា១១៦៨ កថាខណ្ឌទី១)។ ក្នុងករណី អនីតិជន ធ្វើមតកសាសន៍ តើអ្នកតំណាងដែលច្បាប់បានកំណត់ អាចលុបចោលមតកសាសន៍នោះដែរឬទេ ?

# ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍





- តើជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ អាចធ្វើមតកសាសន៍បានដែរឬទេ?
- មាត្រា១១៦៨ ពុំបានចែងកម្រិតសិទ្ធិរបស់ជនទាំងពីរប្រភេទនេះទេ ប៉ុន្តែចំពោះជននៅក្រោមរបបអាណាព្យាបាលទូទៅ ដើម្បីអាចធ្វើ មតកសាសន៍បាន លុះត្រាតែបានបំពេញតាមមាត្រា ១១៦៧។

# ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍



- សមត្ថភាពនាពេលធ្វើមតកសាសន៍៖ ម្ចាស់បណ្ដាំ ត្រូវមានសមត្ថភាព នាពេលធ្វើមតកសាសន៍ (មាត្រា១១៦៩នៃក្រម)។
- ឧទាហរណ៍ បុគ្គលម្នាក់ មានអាយុ៣០ឆ្នាំ គាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើមតកសាសន៍ ប៉ុន្តែ គាត់បានធ្វើមតកសាសន៍ ក្នុងស្ថានភាពដែលគាត់ស្រវឹងជោគជាំ ក្នុងករណីនេះ គាត់ពុំមានសមត្ថភាពនាពេលធ្វើមតកសាសន៍នោះទេ។

# ១. សមត្ថភាពក្នុងការធ្វើមតកសាសន៍







ទទួលបាន
អាត្តាធីនភាព







ត្រូវបំពេញតាម
ទម្រង់ នៃមាត្រា
១១៣៦

# ១. សមត្ថភាពក្នុងការផ្ញើមតកសាសន៍








ត្រូវបំពេញតាមមាត្រា ១១៧៩

# ២. ទម្រង់នៃមតកសាសន៍

ការបង្កើតមតកសាសន៍ គឺជាសេរីភាពរបស់ម្ចាស់បណ្តាំ ប៉ុន្តែ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ក្រោយពេលគាត់ទទួលមរណភាព ច្បាប់តម្រូវឲ្យ មតកសាសន៍ ត្រូវតែបង្កើតឡើងក្នុងទម្រង់ ជាក់លាក់ណាមួយ ។

តើមតកសាសន៍មាន ប៉ុន្មានទម្រង់?

# ២. ទម្រង់នៃមតកសាសន៍

**មតកសាសន៍តាមទម្រង់ធម្មតា**
- មតកសាសន៍ដោយលិខិតឯកជន មាត្រា ១១៧៤
- មតកសាសន៍ដោយលិខិតសម្ងាត់ មាត្រា១១៧៥
- មតកសាសន៍ដោយលិខិតយថាភូត មាត្រា១១៧៣

**មតកសាសន៍តាមទម្រង់ពិសេស**
- មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំងជាអាទិ៍ មាត្រា១១៧៨
- មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់ជាបន្ទាន់ដល់អាយុជីវិត មាត្រា១១៧៧

**បន្ថែម**

មាត្រា១១៧៦
មាត្រា១១៧៩
មាត្រា១១៨១

# ២. ទម្រង់នៃមតកសាសន៍



មតកសាសន៍ដោយលិខិតឯកជន
មាត្រា ១១៧៤

- មតកសាសន៍ ដោយលិខិតឯកជន
- (១) ម្ចាស់បណ្ដាំ ត្រូវសរសេរដោយផ្ទាល់ដៃ
- (២) ត្រូវមានចុះហត្ថលេខា និងកាលបរិច្ឆេទ
- (៣) ការបន្ថែម ឬ លុប ឬ កែប្រែផ្សេងទៀត ត្រូវបានហាមឃាត់ លើកលែងតែម្ចាស់បណ្ដាំ បង្ហាញនូវកន្លែងកែប្រែ ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែ និងចុះហត្ថលេខា។

# ២. ទម្រង់នៃមតកសាសន៍





# ២. ទម្រង់នៃមតកសាសន៍

**បញ្ហា ៖**

- មតកសាសន៍ ដែលផ្តិតស្នាមម្រាមដៃ ជំនួស ហត្ថលេខា
- មតកសាសន៍ ដែលធ្វើឡើងដោយមានវត្តមានរបស់សាក្សី
- មតកសាស៍ដែលធ្វើឡើងដោយមានប្រថាប់ត្រាមេធាវី
- មតកសាសន៍ដែលធ្វើឡើងជាច្រើនច្បាប់
- មតកសាសន៍ ដែលគ្មានចុះកាលបរិច្ឆេទ

# ២. ទម្រង់នៃមតកសាសន៍




- មតកសាសន៍ ដោយលិខិតយថាភូត ៖
- ម្ចាស់បណ្ដាំ ថ្លែងអំពីខ្លឹមសារនៃមតកសាសន៍ នៅចំពោះមុខ
- សារការី សាក្សីយ៉ាងតិច២ នាក់។
- ម្ចាស់បណ្ដាំ សាក្សី សារការី ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

មតកសាសន៍ដោយលិខិតយថាភូត មាត្រា១១៧៣

# ២. ទម្រង់នៃមតកសាសន៍




មតកសាសន៍ដោយលិខិតសម្ងាត់ មាត្រា១១៧៥

- មតកសាសន៍ដោយលិខិតសម្ងាត់៖
- (១)ម្ចាស់បណ្តាំ ធ្វើមតកសាសន៍
- ហើយដាក់ក្នុងស្រោមបិទជិត។
- (២) ម្ចាស់បណ្តាំ ត្រូវយកលិខិតដែលបានបិទជិតនោះ ឲ្យសារការីចុះនិទ្ទេស ។

# ៣. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

| | |
|---|---|
| ការកំណត់ចំណែកមត៌ក | មាត្រា១១៨២ |
| ការកំណត់វិធីបែងចែកមត៌ក | មាត្រា១១៨៣ |
| អនុប្បទានទ្រព្យសម្បត្តិ | មាត្រា ១១៨៤<br>មាត្រា ១១៨៥ |
| ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ | មាត្រា១១៨៦ |
| ផ្សេងៗ | មាត្រា ១១៨៧ |

# ៣. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

- **ការកំណត់ចំណែកមតិក ៖**

ឧ. ទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ (លុយ ដី ឡាន ម៉ូតូ) ប្រគល់ឲ្យកូនទាំង៣នាក់របស់ខ្ញុំក្នុងចំណែកស្មើគ្នាៗ ។

ឧ. ដីដែលមានទីតាំងនៅភ្នំពេញ ខ្ញុំប្រគល់ឲ្យ កូនខ្ញុំទាំងបីនាក់ ក្នុងចំណែកស្មើៗគ្នា ។

ឧ. លុយដែលមានចំនួន៥០០០០ដុល្លារ នៅក្នុងធានា Y ខ្ញុំប្រគល់ ឲ្យកូនខ្ញុំទាំងបីនាក់ ក្នុងចំណែកស្មើៗគ្នា។

# ៣. ចំណុចដែលត្រូវសរសេរក្នុង មតកសាសន៍



# A B C

# ៣. ចំណុចដែលត្រូវសរសេរក្នុង មតកសាសន៍



# ៣. ចំណុចដែលត្រូវសរសេរក្នុង មតកសាសន៍

**វិធីបែងចែកមត៌ក**



សន្តតិជនA



សន្តតិជនB



សន្តតិជនC

# ៣. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

- **បញ្ហា៖**
- នៅក្នុងមតកសាសន៍ខ្លះ មតកជន សរសេរមិនច្បាស់ ដែលយើងមិនអាចកំណត់បានថាជាវិធីបែងចែកមត៌ក ឬ ជាអច្ច័យទាន ហេតុនេះត្រូវប្រើប្រាស់ការសន្មតដើម្បីកំណត់ឲ្យបានច្បាស់(មាត្រា១១៨៥)។

| | | |
|---|---|---|
| | មតកជនX មានទ្រព្យសម្បត្តិ ដី និងលុយ សរុបចំនួន១៥០០ ដុល្លារ មានកូន A B C មតកសាសន៍កំណត់ថា កូន Aទទួលបាននូវដី ដែលមានតម្លៃ ៧០០ដុល្លារ ។ | |

# ៣. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

មតកជនX មានទ្រព្យសម្បត្តិ ដី និងលុយសរុប ១៥០០ ដុល្លារ មានកូន A B C

មតកសាសន៍កំណត់ថា កូន A ទទួលបាននូវដី ដែលមានតម្លៃ ៧០០ ដុល្លារអាមេរិក។

- តើក្នុងមតកសាសន៍ នេះជាការកំណត់វិធីបែងចែកមត៌ក ឬជាអច្ច័យទាន?
- ដោយសារ ភាពមិនច្បាស់លាស់ហេតុនេះមាត្រា១១៨៥
- កថាខណ្ឌទី១ សន្មតថា
- ***ជាវិធីបែងចែកមត៌ក***

# ៣. ចំណុចដែលត្រូវសរសេរក្នុងមតកភាគសន៍

- បើតម្លៃនៃទ្រព្យដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ក របស់សន្តតិជន នោះត្រូវសន្មតថា បានកំណត់ចំណែកមត៌ក (មាត្រា១១៨៥)។ ហេតុនេះ កូន A ដែលទទួលបាននូវដី មានតម្លៃ ៧០០ ដុល្លារអាមេរិក ត្រូវបានសន្មតថា ជាការកំណត់ចំណែកមត៌ក

- តើលុយដែលនៅសល់ ៨០០ដុល្លារ ត្រូវបែងចែកដូចម្តេច? តើ A អាចទទួលបានចំណែកពីលុយនោះដែរឬទេ?

# ៣. ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍

- ដោយសារ A ទទួលបានដី ដែលមានតម្លៃ ៧០០ដុល្លារ ដែលសន្មតថា មតកសាសន៍បានកំណត់អំពីវិធីបែងចែកមត៌ក ហើយតម្លៃនៃដីនោះ មានចំនួនលើសពី ចំណែកមត៌ករបស់សន្តតិជន
- (៥០០ដុល្លារ) ត្រូវបានសន្មតថា បានកំណត់អំពីចំណែកមត៌ក ហេតុនេះA មិនអាចទទួលបានចំណែកពីលុយ៨០០ដុល្លារនោះទេ។ លុយដែលនៅសល់៨០០ដុល្លារ ត្រូវបែងចែកស្មើ គ្នារវាងសន្តតិជន B & C ។
- សន្តតិជន អាចទទួលបានអច្ច័យទាន លុះត្រាតែមានខ្លឹមសារច្បាស់លាស់ជាអច្ច័យទាន ដូចជា មតកជន X ផ្តល់អច្ច័យទាន...

# ៤. ការលុបចោលមតកសាសន៍

ម្ចាស់បណ្ដាំ អាចលុបចោលមតកសាសន៍ មួយភាគ ឬ ទាំងមូល ពេលណាក៏បាន ប៉ុន្តែម្ចាស់បណ្ដាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍បានឡើយ (មាត្រា១១៨៨ នៃក្រម)។

តើការលុបចោលមតកសាសន៍ ត្រូវធ្វើតាមវិធីណាខ្លះ?

# ៤. ការលុបចោលមតកសាសន៍

ធ្វើមតកសាសន៍ថ្មី
(លុបចោលមតកសាសន៍ដោយទម្រង់)

មាត្រា១១៨៩

ចាត់ចែងកម្មវត្ថុនៃមត៌ក
(លុបចោលមតកសាសន៍ដោយការចាត់ចែងនាពេលនៅរស់)

មាត្រា១១៩០

ការបំផ្លាញច្បាប់ដើមមតកសាសន៍
(ការលុបចោលដោយការបដិសេធមតកសាសន៍) ឬ បំផ្លាញកម្មវត្ថុនៃមតកសាសន៍

មាត្រា១១៩១

# ៤. ការលុបចោលមតកសាសន៍

ម្ចាស់បណ្តាំ ធ្វើមតកសាសន៍ថ្មី ៖ ការធ្វើមតកសាសន៍ថ្មីនេះ ម្ចាស់បណ្តាំអាចបញ្ជាក់ច្បាស់អំពីការលុបចោល មតកសាសន៍មុន ឬ ធ្វើមតកសាសន៍ថ្មី ដែលមានខ្លឹមសារ ផ្ទុយពីមតកសាសន៍មុន ។ មតកសាសន៍ថ្មី អាចបង្កើតឡើងតាមទម្រង់ ផ្សេងពីមតកសាសន៍មុនបាន ឧ. មតកសាសន៍មុន ធ្វើឡើងតាមទម្រង់យថាភូត មតកសាសន៍ថ្មី ធ្វើឡើងតាមទម្រង់លិខិតឯកជន មតកសាសន៍ថ្មី មានអានុភាពលុបចោល នូវមតកសាសន៍ចាស់ ។

មាត្រា១១៨៩ នៃក្រម

# ៤. ការលុបចោលមតកសាសន៍



ទី១



ទី២

# ៤. ការលុបចោលមតកសាសន៍

- ការចាត់ចែងទ្រព្យដែលជាកម្មវត្ថុនៃមត៌កនាពេលនៅរស់៖
- ម្ចាស់បណ្តាំមិនចាំបាច់ធ្វើមតកសាសន៍ថ្មីដើម្បីលុបមតកសាសន៍ចាស់ទេ ប៉ុន្តែស្ថានភាពនេះ ច្បាប់ចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ត្រង់ផ្នែកនោះ ។ ឧ. ម្ចាស់បណ្តាំ សរសេរក្នុងមតកសាសន៍ថា ដីL ត្រូវបានឲ្យកូនA ប៉ុន្តែ ១ខែក្រោយមក ម្ចាស់បណ្តាំបានលក់ដីនោះ ក្នុងករណីនេះ ទោះបីជា ម្ចាស់បណ្តាំមិនបានលុបចោលចំណុចនោះក៏ដោយ ការចាត់ចែងកម្មវត្ថុនៃមត៌ករបស់ម្ចាស់បណ្តាំ មានអានុភាពលុបចោលនូវមតកសាសន៍។

# ៤. ការលុបចោលមតកសាសន៍



ទី១




ទី២

កិច្ចសន្យា
លក់ទិញ



# ៤. ការលុបចោលមតកសាសន៍

## បញ្ហា ៖




ក្នុងករណីមតកសាសន៍ចែងថា ឡានរបស់ខ្ញុំមួយគ្រឿងដែលមានតម្លៃ ៨០០០០ដុល្លារ ឲ្យទៅកូនB ប៉ុន្តែក្រោយមក ឡាននោះ ត្រូវ Yខ្ចីប្រើ និងបានបង្កគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឲ្យ ឡាន រងការខូចខាត តើចាត់ទុកថា មតកសាសន៍នោះ ត្រូវបានលុបចោលឬទេ?

ករណីនេះ ពុំចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ទេ ហើយទោះបីជាសន្តតិជន មិនអាចធ្វើលទ្ធកម្មចំពោះវត្ថុនោះក៏ដោយ សន្តតិជន អាចទាមទារសំណងពីតតិយជនដែលបានធ្វើឲ្យខូចខាតវត្ថុនោះ មាត្រា១២០៩ នៃក្រម។

# ៤. ការលុបចោលមតកសាសន៍



My Dearest Robert

If only I were a clever woman I could describe to you my gorgeous bird how you unite in yourself the beauties of form plumage and song!

I would tell you that you are the greatest marvel of all ages and I should only be speaking the simple truth. But to put all this into suitable words my superb one I should require a voice far more harmonious than that which is bestowed upon my species for I am the humble owl that you mocked at only lately therefore it cannot be

I will not tell you to what degree you are dazzling and to the birds of sweet song who as you know are none the less beautiful and appreciative

I love you I love you my darling I can not reiterate it too often I can never express it as much as I feel it

You are not only the solar spectrum with the seven luminous colours but the sun himself that i … and revivifies! This is what you … ly woman that adores you

មាត្រា១១៩១ នៃក្រម

ម្ចាស់បណ្តាំ បំផ្លាញមតកសាសន៍ ឬ កម្មវត្ថុនៃមត៌កៈ

ក្នុងករណីម្ចាស់បណ្តាំ បំផ្លាញមតកសាសន៍ច្បាប់ដើម ដូចជា ហែកមតកសាសន៍ចោល គូសចោល ឬ ធ្វើឲ្យមើលមិនយល់ នូវខ្លឹមសារនៃមតកសាសន៍ ចាត់ទុកថា ម្ចាស់បណ្តាំ លុបចោលមតកសាសន៍ ។ ឧ. មតកសាសន៍ចែងថា សណ្ឋាគារនៅរតនៈគិរី ត្រូវប្រគល់ឲ្យកូន C បន្ទាប់មក ម្ចាស់បណ្តាំបានយក ទឹកលុបទៅលុបលើត្រង់ពាក្យនោះ ឬ គូសចោល ឬ ហែកចោលមតកសាសន៍ ផ្នែកនេះត្រូវបានលុបចោល។

# ៤. ការលុបចោលមតកសាសន៍

បញ្ហា៖

ក្នុងករណី សន្និតជន បានបំផ្លាញមតកសាសន៍ ឬ កែប្រែមតកសាសន៍ តើចាត់ទុកថា មតកសាសន៍បាត់បង់អានុភាពដែរឬទេ ?

មាត្រា១១៩១ អនុវត្តចំពោះតែករណីដែលមតកជនបំផ្លាញមតកសាសន៍ តែប៉ុណ្ណោះ ហេតុនេះ បើតតិយជន ជាអ្នកបំផ្លាញមតកសាសន៍ជាគោលការណ៍ មតកសាសន៍មិនបាត់បង់អានុភាពនោះទេ។ មានន័យថា បើការបំផ្លាញនៅអាចមើលខ្លឹមសារយល់ នោះ ត្រូវអនុវត្តតាមមតកសាសន៍ ប៉ុន្តែ បើមិនអាចមើលយល់ទេ មតកសាសន៍ ត្រូវបាត់បង់អានុភាព ហេតុនេះ ត្រូវអនុវត្តសន្តតិកម្មតាមច្បាប់ ឬ សន្និតជនធ្វើការពិភាក្សាគ្នាធ្វើការបែងចែកមត៌ក។

# II. ដំណាក់កាលបង្កើតអានុភាព នៃមតកសាសន៍

មតកសាសន៍ បង្កើតអានុភាពនៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព ប៉ុន្តែបើមតកសាសន៍ មានភ្ជាប់នូវលក្ខខណ្ឌបង្អង់ មតកសាសន៍មានអានុភាព នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ហើយ លក្ខខណ្ឌ បង្អង់នោះ ត្រូវបានបំពេញ។

មាត្រា១១៩៤ នៃក្រមរដ្ឋប្បវេណី

# II. ដំណាក់កាលបង្កើតអានុភាព នៃ មតកសាសន៍

៤. មតកសាសន៍ចែងថា ផ្ទះតែមួយគត់របស់ខ្ញុំ ខ្ញុំនឹងប្រគល់ឲ្យ ក្មួយប្រុសរបស់ខ្ញុំ នៅពេលដែលគេមានអាយុ២០ឆ្នាំ មតកសាសន៍នេះ មានអានុភាពនៅពេលដែលក្មួយនោះមានអាយុ២០ឆ្នាំ ហើយ ម្ចាស់បណ្តាំបានទទួលមរណភាព។

# II. ដំណាក់កាលបង្កើតអានុភាព នៃមតកសាសន៍

៤. មតកជនX ទទួលមរណភាព ០១.០១.២០១៧ ហើយបានបន្សល់ទុកនូវលិខិតបណ្តាំ ចែងថា៖

ប្រគល់លុយ ២០០០០ដុល្លារ នៅក្នុងធនាគារ ក ឲ្យ A

ប្រគល់ដីL ឲ្យទៅ B ក្នុងករណីនេះ B មានកម្មសិទ្ធិលើដីL នៅថ្ងៃទី ០១.០១.២០១៧ ហើយAទទួលបានលុយចំនួន២០០០០ដុល្លារ ទោះបីជា ខ្លួនមិនទាន់បានទៅដកលុយនោះពីធនាគារក៏ដោយ។

មាត្រា១១៩៥ នៃក្រម

# II. ដំណាក់កាលបង្កើតអានុភាព នៃ មតកសាសន៍




មតកជនទទួលមរណភាព
០១.០១.២០១៧



មត៌ក

សន្តតិជន
០១.០១.២០១៧

# II. ដំណាក់កាលបង្កើតអានុភាព នៃមតកសាសន៍

- ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដោយមូលហេតុសន្តតិកម្មតាមមតកសាសន៍ ត្រូវមានអានុភាពនៅពេលដែលមតកជនទទួលមរណភាព ឬ លក្ខខណ្ឌបង្អង់ត្រូវបានបំពេញ ហេតុនេះ សន្តតិជន នឹងទទួលបានកម្មសិទ្ធិលើអចលនវត្ថុ នៅពេលដែលមតកសាសន៍បង្កើតអានុភាព ទោះបីជា មិនទាន់បានចុះបញ្ជីផ្ទេរកម្មសិទ្ធិពីឈ្មោះរបស់មតកជន មកឈ្មោះ សន្តតិជនក៏ដោយ។

# III. ដំណាក់កាលអនុវត្តមតកសាសន៍

| | |
|---|---|
| ១ | ការបញ្ជាក់មតកសាសន៍ |
| ២ | ការពិភាក្សាបែងចែកមត៌ក |
| ៣ | ធ្វើនីតិវិធីផ្សេងៗដើម្បីទទួលទ្រព្យជាក់ស្តែង |

# III. ដំណាក់កាលអនុវត្តមតកសាសន៍

១ ការបញ្ជាក់មតកសាសន៍

ការបញ្ជាក់មតកសាសន៍ តាមមាត្រា១២១៣ គឺជាការបញ្ជាក់អំពីអត្ថិភាព នៃមតកសាសន៍ ចំនួនទំព័រ និងរូបរាង ឬ ស្ថានភាពនៃ មតកសាសន៍ ពេលគឺ មិនមែនបញ្ជាក់អំពីភាពត្រឹមត្រូវ ឬ មោឃភាព នៃមតកសាសន៍ឡើយ ។

ការបញ្ជាក់ត្រូវធ្វើឡើងតាមនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។

# III. ដំណាក់កាលអនុវត្តមតកសាសន៍

- គ្រប់ប្រភេទនៃមតកសាសន៍ទាំងអស់ ត្រូវ ធ្វើការបញ្ជាក់តាមបញ្ញត្តិនៃ មាត្រា១២១៣ លើកលែងតែ មតកសាសន៍ដោយលិខិតយថាភូត។

- ចំពោះមតកសាសន៍តាមទម្រង់ពិសេស (មតកសាសន៍របស់ជនដែលជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត) ត្រូវធ្វើការបញ្ជាក់ចំនួន ២ដង គឺ បញ្ជាក់តាមបញ្ញត្តិនៃមាត្រា១១៧៧ និងបញ្ជាក់តាមបញ្ញត្តិមាត្រា ១២១៣។

# III. ដំណាក់កាលអនុវត្តមតកសាសន៍

២ ការពិភាក្សាបែងចែកមត៌ក

- ជាធម្មតា ក្នុងករណី មានមតកសាសន៍ សន្តតិជន ត្រូវអនុវត្តតាមខ្លឹមសារនៃមតកសាសន៍នោះ ប៉ុន្តែ ប្រសិនបើ មតកសាសន៍មិនបានកំណត់ឲ្យបានច្បាស់លាស់អំពីវិធីបែងចែកមត៌កទេ ដើម្បីអាចបែងចែកទ្រព្យជាក់ស្តែងបាន សន្តតិជនទាំងអស់ អាចធ្វើការពិភាក្សាបែងចែកមត៌ក ផ្សេងពីអ្វីដែលមានកំណត់នៅក្នុងមតកសាសន៍ (មាត្រា១២៦៦)។ ប៉ុន្តែ ក្នុងករណី មិនអាចធ្វើការពិភាក្សាបែងចែកមត៌កបានទេ តុលាការជាអ្នកបែងចែក ។

# III. ដំណាក់កាលអនុវត្តមតកសាសន៍

មតកសាសន៍កំណត់ថា ទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ (ដី លុយ និងឡាន) ត្រូវប្រគល់ឲ្យ កូន ABC

- មតកសាសន៍នេះ មានន័យថា ទ្រព្យសម្បត្តិទាំងអស់ ត្រូវស្ថិតនៅក្នុងស្ថានភាព កម្មសិទ្ធិអវិភាគរបស់ABC ក្នុងករណីនេះ គេអាចធ្វើ ការពិភាក្សាបែងចែកមត៌ក ដោយកំណត់ថា A ទទួលបានដី Bបានលុយ C បានឡាន ។

# III. ដំណាក់កាលអនុវត្តមតកសាសន៍

៣

ធ្វើនីតិវិធីផ្សេងៗដើម្បីទទួលទ្រព្យជាក់ស្តែង

- ជាធម្មតា មត៌ក ត្រូវបានផ្ទេរមកសន្តតិជន នៅពេលដែលមតកជន បានទទួលមរណភាព ប៉ុន្តែ ជាក់ស្តែង យើងត្រូវការបំពេញនីតិវិធីមួយចំនួនដើម្បីទទួលបានទ្រព្យទាំងនោះ។
- ករណីមត៌ក គឺជា លុយដែលមតកជនទុកនៅក្នុងធនាគារ
- តើត្រូវធ្វើដូចម្តេចដើម្បីដកលុយក្នុងធនាគារបាន?

# III. ដំណាក់កាលអនុវត្តមតកសាសន៍

ត្រូវការសេចក្ដីសម្រេចរបស់តុលាការ ទើបធនាគារយល់ព្រមដកលុយឲ្យ

- ១.បង្ហាញ សំបុត្រកំណើត (បញ្ជាក់អំពីអត្តសញ្ញាណរបស់សន្តតិជន) សៀវភៅគ្រួសារ (បញ្ជាក់ចំនួនសន្តតិជន) សំបុត្រមរណភាព (បញ្ជាក់ថាម្ចាស់គណនីបានស្លាប់)
- ២. បង្ហាញ មតកសាសន៍ ឬ កិច្ចព្រមព្រៀងបែងចែកមត៌ក
- ៣.សៀវភៅគណនី លេខគណនី ..... ជាអាទិ៍

# III. ដំណាក់កាលអនុវត្តមតកសាសន៍

ករណីអចលនវត្ថុ តើត្រូវធ្វើនីតិវិធីចុះបញ្ជី ឬ យ៉ាងណា?

ក្នុងករណី ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ពីមតកជន មក សន្តតិជន បង្កើតអានុភាពដោយមិនចាំបាច់ចុះបញ្ជី ។ សន្តតិជន មានកម្មសិទ្ធិលើដី នៅពេលដែលមតកជន បានទទួលមរណភាព (អានុភាពនៃមតកសាសន៍)។ ប៉ុន្តែ ដើម្បីអាចផ្ទេរកម្មសិទ្ធិទៅ តតិយជន ដូចជាករណី សន្តតិជន លក់ដីនោះ ឲ្យទៅតតិយជន លុះត្រា តែបានផ្ទេរពីឈ្មោះមតកជន មកឈ្មោះសន្តតិជន ទើបអាចផ្ទេរកម្មសិទ្ធិពីឈ្មោះសន្តតិជន មកឈ្មោះតតិយជនដែលជាអ្នកទិញបាន។

# III. ដំណាក់កាលអនុវត្តមតកសាសន៍

ត្រូវការសេចក្ដីសម្រេចរបស់តុលាការ ទើបអាចចុះបញ្ជីបាន

ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដោយមូលហេតុសន្តតិកម្ម (សន្តតិកម្មតាមច្បាប់ មតកសាសន៍ ការពិភាក្សាបែងចែកមត៌ក) បើមតកសាសន៍កំណត់ថា ឲ្យដីទៅ A ក្នុងមតកសាសន៍ ដីនោះនឹងក្លាយជាកម្មសិទ្ធិរបស់ A នៅពេលម្ចាស់ទ្រព្យ ឬម្ចាស់បណ្ដាំ បានទទួលមរណភាព ដោយមិនត្រូវការសេចក្ដីសម្រេចរបស់តុលាការនោះទេ។

# ការពិភាក្ស សំនួរ និងចម្លើយ




THANK YOU
for your support!